គណបក្ស សិទ្ធិមនុស្ស
HUMAN RIGHTS PARTY
បំរើ ការពារ កសាង

**កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ**

*ព្រឹត្តិប័ត្រព័ត៌មានប្រចាំសប្តាហ៍*   *ថ្ងៃសុក្រ ទី២០ ខែមីនា ឆ្នាំ២០០៩*   *ព្រឹត្តិប័ត្រលេខ៧៧ ឆ្នាំទី២*

| មាតិកាព័ត៌មាន | ទំព័រ |
|---|---|
| -រាល់កិច្ចការតូចធំស្ថិតនៅលើកណ្តាប់ដៃរបស់នាយករដ្ឋមន្ត្រី | ១ |
| -ការចុះជួបសំណេះសំណាលរបស់ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សនៅតាមមូលដ្ឋាន | ២ |
| -រដ្ឋាភិបាលតែងតែច្រានចោលរបាយការណ៍សិទ្ធិមនុស្សស្តីពីកម្ពុជា | ២ |
| -ទូកនេសាទយួនចតពេញទន្លេនៅមុខផ្សារកំពង់ហៅ | ៣ |
| -វិបត្តិសេដ្ឋកិច្ចធ្វើឱ្យប៉ះពាល់ដល់វិស័យកសិកម្មនៅកម្ពុជា | ៤ |

## រាល់កិច្ចការតូចធំស្ថិតនៅលើកណ្តាប់ដៃរបស់នាយករដ្ឋមន្ត្រី

មតិជាតិ និងអន្តរជាតិសង្គមស៊ីវិលបានលើកឡើងថា ប្រជាពលរដ្ឋដែលរងការរំលោភសិទ្ធិលំនៅដ្ឋាន រំលោភដីធ្លី រងការគាបសង្កត់ពីអាជ្ញាធរមានអំណាចតែងតែពី ស្រែកអំពាវនាវឱ្យលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ជួយដោះស្រាយ និងអន្តរាគមន៍ ដោយប្រជាពលរដ្ឋមិនពឹងពាក់ទៅលើអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចនោះទេ ។

ករណីនេះត្រូវបានលោក **ប៉ែន សុវណ្ណ** ប្រធានគណៈកម្មាធិការវិន័យរបស់គណបក្សសិទ្ធិមនុស្ស សំគាល់ឃើញថាសព្វថ្ងៃប្រជាពលរដ្ឋខ្មែរមិនសូវយល់អំពីច្បាប់ហើយអ្នកណាជាអ្នកគោរពច្បាប់ករណីនេះធ្វើឱ្យប្រជាពលរដ្ឋអស់សង្ឃឹម ម្យ៉ាងទៀតបើសិនប្រជាពលរដ្ឋដែលមានបញ្ហាទៅពឹងតុលាការ ហើយមិនមានលុយកាក់ផងនោះពួកគាត់មិនហ៊ានទៅពឹងតុលាការនោះឡើយ ។ មួយវិញទៀតបើយើងមានលុយ ហើយប៉ុន្តែលុយមានមិន ដល់គេក៏មិនសំរេចផលអ្វីដែរនាំឱ្យខាតទាំងលុយទាំងកំលាំងពីព្រោះតុលាការមិនឯករាជ្យ ។

លោក **ប៉ែន សុវណ្ណ** បានបន្តថា ដោយសារតុលាការមិនឯករាជ្យ និងច្បាប់ទំលាប់ត្រឹមត្រូវ ទើបដូច្នេះហើយទើបអាជ្ញាធរមូលដ្ឋានប្រើអំពើរំលោភបំពានមកលើប្រជាពលរដ្ឋដូចជា ដីធ្លីជាដើម ។

លោក **ប៉ែន សុវណ្ណ** ឥស្សរជនគណបក្សសិទ្ធិមនុស្ស និងបីតា៧មករា និង ២ធ្នូ ផងនោះបានបញ្ជាក់បន្ថែមថា ប្រព័ន្ធគ្រប់គ្រងស្រុកខ្មែរ គឺរដ្ឋអំណាចជារបស់បក្សមិនមែនរដ្ឋអំណាចជារបស់ប្រជាពលរដ្ឋនោះទេ ។ លោកបន្ថែមទៀតថារដ្ឋអំណាចនៅតាមមូលដ្ឋានសព្វថ្ងៃនេះពួកគេដណ្តើមគ្នារស់ ពុំមែនចែករំលែកគ្នារស់នេះទេ ។ នៅតាមមូលដ្ឋានលោកសង្កេតថាប្រជាពលរដ្ឋខ្វល់ខ្វាយ

និងបញ្ហាជំងឺដង្កាត់ដែល លោកចំណាយច្រើនក្នុងការសំរាកព្យាបាលនៅមន្ទីរពេទ្យរដ្ឋ ។

## ការចុះជួបសំណេះសំណាលរបស់ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សនៅតាមមូលដ្ឋាន

ជានិច្ចជាកាលថ្នាក់ដឹកនាំ គណបក្សសិទ្ធិមនុស្សតែងតែចុះជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ សកម្មជនរបស់បក្សនៅតាមមូលដ្ឋានគ្រប់ខេត្តក្រុង ទាំងមុនដំណាក់កាលបោះឆ្នោត ក្រោយបោះឆ្នោត និងទៅអនាគតផងដែរ ។

លោក **កឹម សុខា** គណបក្សសិទ្ធិមនុស្សដែលលេចមុខជាងគេក្នុងការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ នៅតាមមូលដ្ឋានបានថា គណបក្សសិទ្ធិមនុស្ស ជាគណបក្សរបស់ប្រជាពលរដ្ឋកើតប្រជាពលរដ្ឋដើម្បីប្រជាពលរដ្ឋ ដូច្នេះមានន័យថា យើងត្រូវចុះទៅសួរសុខទុក្ខ និងស្វែងយល់ពីតំរូវការរបស់ពួកគាត់ ដែលនេះមានគណបក្សខ្លះទៅរកប្រជាពលរដ្ឋតែមុនបោះឆ្នោត ក្រោយបោះឆ្នោតហើយគេមិនទៅជិតនោះទេ ។ ដោយម្យ៉ាងទៀត គណបក្សសិទ្ធិមនុស្ស មិនមែនដើម្បីតែការបោះឆ្នោតមួយប៉ុណ្ណោះទេ ពោលគឺដើម្បីការពារផលប្រយោជន៍ប្រជាពលរដ្ឋ បំរើប្រជាពលរដ្ឋទោះជាមុនបោះឆ្នោត ឬក្រោយបោះឆ្នោតក៏ដោយគឺយើងឋិតនៅប្រចាំជាមួយប្រជាពលរដ្ឋ ។

លោក **កឹម សុខា** សមាជិករដ្ឋសភាគណបក្សសិទ្ធិមនុស្សបានបញ្ជាក់បន្ថែមថា តាមអ្វីដែលលោកបានជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋនៅតាមជនបទស្រុកស្រែចំការលោកឃើញថាបញ្ហាចម្បងក្តីកង្វល់ធំរបស់ប្រជាពលរដ្ឋ គឺជីវភាពរស់នៅជាពិសេសស្បៀងអាហារដែលកន្លែងខ្លះប្រជាពលរដ្ឋធ្វើស្រែស្រូវ មិនបានគ្រប់គ្រាន់នៅពេលប្រមូលផល ហើយកសិកផលមានតំលៃទាប ។ រីឯវត្ថុធាតុដើមដែលបងប្អូនយកមកផលិតដូចជា ជី ពូជ ប្រេង មានតំលៃខ្ពស់ដែលជាហេតុធ្វើឱ្យមានការលំបាកដល់បញ្ហាជីវភាព ។

លោក **កឹម សុខា** បានអះអាងទៀតថាក្រៅពីជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក៏នៅមានបញ្ហានយោបាយ គឺមានការរើសអើងនយោបាយទៅតាមមូលដ្ឋាន ជាឧទាហរណ៍ប្រសិនបើសកម្មជនគាំទ្រគណបក្សសិទ្ធិមនុស្ស ទៅពឹងពាក់អាជ្ញាធរមូលដ្ឋានគឺគេតែងតែរើសអើង ។ ដូច្នេះអាជ្ញាធរមូលដ្ឋានមិនស្គាល់តួនាទីរបស់ខ្លួន និងមិនមានការទទួលខុសត្រូវហើយបែរជាមានការបែងចែកបក្សពួកទៅតាមកំអែលកុម្មុយនិស្តដដែល ។

លោក **កឹម សុខ** អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាមបានកត់សំគាល់ទៀតថា គណបក្សសិទ្ធិមនុស្ស មានគោលការច្បាស់លាស់លើវិស័យសេដ្ឋកិច្ចដោយផ្តោតទៅលើកសិកម្ម ពីព្រោះប្រជាពលរដ្ឋ៨៥ភាគរយជាកសិករ ។ ដូចជាជួយវត្ថុធាតុដើមអោយមានតំលៃថោក និងផ្តល់ប្រាក់កំចីជាដើមទុនជូនប្រជាពលរដ្ឋដោយការប្រាក់ទាប ម្យ៉ាងទៀតជួយរកទីផ្សារកសិផលជូនប្រជាពលរដ្ឋសំខាន់ជាងនេះគឺយើងការពារកម្មសិទ្ធិធីធ្លី ជូនប្រជាពលរដ្ឋដើម្បីឱ្យក្លាយជាកម្មសិទ្ធិស្របច្បាប់ ។

លោកក៏បានបញ្ជាក់យ៉ាងខ្លីថា ប្រសិនបើគណបក្សសិទ្ធិមនុស្សដឹកនាំរដ្ឋាភិបាល គឺយើងដាច់ខាតមិនឱ្យមានការរើសអើងប្រកាន់បក្សពួកនោះទេ ពីព្រោះរដ្ឋាភិបាលរបស់យើងជារដ្ឋាភិបាលរបស់ប្រជាពលរដ្ឋ មិនមែនជារដ្ឋាភិបាលរបស់បក្ស គឺខុសពីអ្នកកាន់អំណាចបច្ចុប្បន្ន ។

## រដ្ឋាភិបាលតែងតែច្រានចោលរបាយការណ៍សិទ្ធិមនុស្សស្តីពីកម្ពុជា

រដ្ឋាភិបាលតែងតែបដិសេធ អំពីរបាយការណ៍សិទ្ធិមនុស្សរបស់អង្គការក្នុងស្រុក និងរបាយការណ៍សិទ្ធិមនុស្សរបស់សហគមន៍អន្តរជាតិ ។ តួយ៉ាងកាលពីចុងខែកុម្ភៈកន្លងទៅក្រសួងការ

បរទេសសហរដ្ឋអាមេរិកបាន ទំលាយរបាយការណ៍អាស្រូវស្តីពីសិទ្ធិមនុស្សឆ្នាំ២០០៨ ដោយក្នុងរបាយការណ៍នោះបាននិយាយអំពីអំពើពុករលួយបានរីករាលដាលនៅកម្ពុជាអ្នកជាប់ឃុំឃាំងត្រូវបានគេរំលោភសិទ្ធិ កំលាំងសិន្តិសុខសំលាប់មនុស្សក្រៅប្រព័ន្ធតុលាការ និងធ្វើសកម្មភាពដោយគ្មានទោសពៃ ។ល។ ប៉ុន្តែរបាយការណ៍របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ត្រូវបានក្រសួងការបរទេសខ្មែរបដិសេធចោលទៅវិញ ។

កាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ ប្រមុខរដ្ឋាភិបាលកម្ពុជា លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានថ្លែង នៅក្នុងសិក្ខាសាលាស្តីពីការទប់ស្កាត់ជំងឺគ្រុនផ្តាសាយបក្សីក្នុងក្រុងភ្នំពេញ លោកមានប្រសាសន៍ថា លោកបានប្រាប់ទៅលោកកូហ្វីអាណាន់អគ្គលេខាធិការអង្គការសហប្រជាជាតិកាលពីឆ្នាំ២០០៥ ថា បុគ្គលិកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបន្តិរះគន់ប្រទេសកម្ពុជា ដើម្បីធានាការងារបន្ត ។ លោកមិនសង្ឃឹមថា និងមានរបាយការណ៍សិទ្ធិមនុស្សវិជ្ជមានអំពីកម្ពុជានោះទេ ប្រសិនបើពួកគេរាយការណ៍ល្អអំពីសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ក្រុមមន្ត្រីទាំងនោះក្នុងក្រុងភ្នំពេញនឹងបាត់បង់ការងារ ។

លោក **ច័ន្ទ សូវេត** មន្ត្រីស៊ើបអង្កេតជាន់ខ្ពស់នៃសមាគមអាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជាបានបញ្ជាក់ថាធម្មតាសង្គមស៊ីវិល ដូចជាអង្គទូតនានាដែលបានស្រាវជ្រាវឃើញថាស្ថានភាពសិទ្ធិមនុស្ស បានកើតឡើងហើយតែបែរជាមិនចាត់វិធានការ ហើយសកម្មភាពដែលធ្វើឡើងស្តែងចេញពីមន្ត្រីអាជ្ញាធរសាធារណៈប្រព្រឹត្តរំលោភលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ។ លោកបន្តថា របាយការណ៍សិទ្ធិមនុស្ស គឺជារបាយការណ៍មួយដែលមិនទាមទារយកអំណាច ឬ បុណ្យសក្តិនោះទេ ប៉ុន្តែប្រការនោះត្រូវបានភ្នាក់ងាររដ្ឋចោទថា បើមិនធ្វើរបាយការណ៍បែបនេះតើធ្វើម្តេចនឹងបានជំនួន ដែលបញ្ហានេះវាគ្រាន់តែជាលេសប៉ុណ្ណោះ ។

លោក **ច័ន្ទ សូវេត** បានបញ្ជាក់បន្ថែមថា របាយការណ៍សិទ្ធិមនុស្សគឺផ្អែកទៅលើស្ថានភាពនៃការពិត ដោយមិនទាញយកកំរៃ មិនបានទាញយកអំណាច ឬសកម្មភាពល្មើសច្បាប់ដូច្នេះរបាយការណ៍សិទ្ធិមនុស្ស គឺសម្លឹងមើលអំពីការខ្វះចន្លោះ និងលើកសំណើដើម្បីដាក់ជូនរដ្ឋាភិបាលឱ្យកែលំអរតាំងពីវិស័យច្បាប់ការអនុវត្តន៍ច្បាប់ និងប្រព័ន្ធតុលាការ ។

## ទូកនេសាទយួនចតទទឹងទន្លេ នៅមុខផ្សារកំពង់ហៅ

នៅមុខផ្សារកំពង់ហៅ ក្នុងភូមិកំពង់បឹង ឃុំកំពង់ហៅ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង មានប្រជាកសិករជាច្រើនបានរអ៊ូរទាំ និងធុញទ្រាន់ចំពោះទូកនេសាទរបស់យួនប្រមាណ៥គ្រឿងចូលចតពាំងមិនឱ្យទូកកសិករខ្មែរ ដែលដឹកកសិផលមកលក់នៅទីផ្សារកំពង់ហៅចូលចតឱ្យបានស្រួលបួលនោះទេ ។ ដោយទូកយួនតែងតែចតពាំងជារៀងរាល់ថ្ងៃ និងម្យ៉ាងទៀតអាជ្ញាធរមន្ត្រីប៉ូលីសប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំកំពង់ហៅត្រូវរ៉ូវជាមួយ និង អ្នកនេសាទយួន ។ សកម្មជនគណបក្សសិទ្ធិមនុស្សនៅស្រុកកំពង់លែងប្រាប់ថាទូកនេសាទយួនដែលជាប្រភេទទូកធំ៤-៥គ្រឿង បានចតជារៀងរាល់ព្រឹកពាំងច្រកផ្លូវមិនឱ្យទូករបស់ខ្មែរ ដឹកបន្លែបង្ការត្រសក់ ពោត មកលក់នៅផ្សារកំពង់ហៅ បានស្រួលចិត្តនោះទេពីព្រោះទូកនេសាទយួនតែងតែបើកបំបុកចូលចត បើទោះជាប៉ះពារខូចខាតដល់ទូកនេសាទខ្មែរក៏ដោយក៏មិនញញើតដែរ ។

សកម្មជនរូបនោះបានបន្តទៀតថា ច្រកចតទូកមានសភាពចង្អៀតផងនោះ ប៉ុន្តែមានទូកយួនឈ្មោះ **យូ សារ៉** បានចតទទឹងទទែងដោយមិនមានការកោតខ្លាច ។ សូម្បីតែមន្ត្រីប៉ុស្តិ៍នគបាលរដ្ឋបាលឃុំកំពង់ហៅ ក៏មិនហ៊ានចាត់វិធាន និងការចតទូកអានាធិបតេយ្យនេះដែរពីព្រោះយួនអាចចតទូកនេះបានអាស្រ័យដោយ

មានមន្ត្រីរាជការកងការពារ ។ ជាពិសេសទៀតនោះគឺយួនបានយកដីត្រីសាច់ទៅសែនព្រេនដល់អាជ្ញាធរពាក់ព័ន្ធ ។

ស្ត្រីអាជីវករលក់អង្ករនៅផ្សារកំពង់ហៅ បានរៀបរាប់ថា ជួនកាលទូកយួន៤គ្រឿង ជួនកាល៥គ្រឿង បានមកទិញជាអាជីពរាល់ថ្ងៃរាល់ខែ ហើយដីចំណតនោះក៏មានទីធ្លាតូចបង្អៀតផងដែរ ហើយទូកយួនធុនធំៗបានចតច្រងេងច្រងាង កាលណាទូកទាំងនោះចូលមកដល់ទូកតូចរបស់ខ្មែរត្រូវតែចាកចេញ ។

យើងមិនអាចទាក់ទង ដើម្បីសុំការបំភ្លឺពីអាជ្ញាធរឃុំកំពង់ហៅ និងប៉ុស្តិ៍នគរបាលឃុំកំពង់ហៅបានទេនៅថ្ងៃនេះ ដោយសារទូរស័ពមិនអាចទាក់ទង់បាន ។

## វិបត្តិសេដ្ឋកិច្ចធ្វើឱ្យប៉ះពាល់ដល់វិស័យកសិកម្មនៅកម្ពុជា

លោក **ប៉ែន សុវណ្ណ** ប្រធានគណៈកម្មាធិការវិន័យ នៃគណបក្សសិទ្ធិមនុស្ស បានប្រាប់ថាសព្វថ្ងៃនេះប្រជាពលរដ្ឋនៅតាមខេត្តតាកែវ ខេត្តកំពត កំពង់ស្ពឺ បានរអ៊ូរទាំ និងព្រួយបារម្ភខណៈពេលកសិផលស្រូវ អង្ករ បន្លែបង្ការ របស់ពួកគាត់លក់បានតំលៃថោក និងការហូរចូលនូវផលិតផលរបស់យួន ដែលធ្វើអោយកសិកផលរបស់កសិករបាត់បង់ទីផ្សារ ឬក៏មានតំលៃទាបប្រជាកសិករ សព្វថ្ងៃជួបនូវវិបត្តិ៣យ៉ាងវិបត្តិទី ១ គឺថាពេលបងប្អូនកំពុងធ្វើស្រែ ប្រេង សាំងជី បានឡើងថ្លៃ លុះពេលប្រជាពលរដ្ឋទទួលផលហើយ ស្រាប់តែតំលៃស្រូវរបស់គាត់ចុះថោកពោល គឺមិនបាន ១000រៀលផងក្នុង១ គ.ក។

លោក **ប៉ែន សុវណ្ណ** បានបន្តទៀតថាវិបត្តិទី ២ គឺកសិករមួយចំនួនដាច់ពោះស្លាប់ដោយសារអត់បាយ បើទោះបីប្រជាពលរដ្ឋសង្ឃឹមទៅលើការលក់ស្រូវក៏មិនអាចធ្វើអ្វីបានដែរ ។ លោកគ្រាន់តែទូរទាត់បំណុលគេក៏មិនគ្រប់គ្រាន់ផងដែរ។

សព្វថ្ងៃនេះប្រជាកសិករដាំដំណាំបានភោគផលសំបូរបែបដូចជាត្រសក់ ប៉េងបោះ ស្ពៃ ប៉ុន្តែបន្លែបង្ការពីស្រុកយួនហូរចូលមកធ្វើឱ្យបន្លែបង្ការរបស់កសិករខ្មែរយើងចុះថោក ។ ករណីនេះលោកបានស្តីបន្ទោសទៅលើអាជ្ញាធរមូលដ្ឋាន និងរាជរដ្ឋាភិបាលមិនចាត់វិធានការទប់ស្កាត់ កុំឱ្យទំនិញយួនហូរចូលស្រុកខ្មែរនោះឡើយ ។ លោកបានកត់សំគាល់បន្តទៀតថា នៅទីអារ៉ាមខ្លះនឹងដាច់ចង្ហាន់ដោយសារប្រជាពុទ្ធបរិស័ទ ចំណុះជើងវត្តមានជីវភាពក្រីក្រ ។

លោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្ស បានមានប្រសាសន៏ថា បច្ចុប្បន្ននេះប្រជាពលរដ្ឋកំពុងមានកង្វល់ធំ និងជីវភាពរស់នៅជាពិសេសស្បៀងធ្វើមិនបានគ្រប់គ្រាន់ និងផលិតផលដែលធ្វើបានហើយមានតំលៃថោក ។ ចំណែកការចិញ្ចឹមសត្វប្រជាពលរដ្ឋមិនមានបច្ចេកទេសចិញ្ចឹមឱ្យបានត្រឹមត្រូវ ដូច្នេះហើយសត្វដែលគាត់ចិញ្ចឹមងាប់ធ្វើឱ្យអ្នកចិញ្ចឹមខាតបង់ ។ លោកបានគូសបញ្ជាក់បន្ថែមថាគណបក្សសិទ្ធិមនុស្ស មានគោលការណ៏ជួយប្រជាកសិករអាទិភាពពីព្រោះប្រជាពលរដ្ឋខ្មែរ ៨៥%ជាកសិករ។


| គ្រប់គ្រងការផ្សព្វផ្សាយ | | |
|---|---|---|
| លោក | ម៉ី សាន | ទូរស័ព្ទលេខ: ០១១ ៩០៤ ០៣១ |
| កញ្ញា | គង់ វណ្ណា | ទូរស័ព្ទលេខ: ០១២ ៨៦៥ ២៥៥ |
| ផ្ទះលេខ៧២-៧៤,ផ្លូវលេខ៥៩៨, សង្កាត់បឹងកក់២,ខណ្ឌទួលគោក,ក្រុងភ្នំពេញ | | |


**កសិផលលក់មិនបានថ្លៃក្នុងពេលវិបត្តិសេដ្ឋកិច្ចពិភពលោកកំពុងជួបបញ្ហា !**